# គម្រោងស្រាវជ្រាវថ្មីរបស់សារមន្ទីរនៃចក្រភពអង់គ្លេស ស្ដីពី ការថតនិងចងក្រងឯកសារ សម្រាប់ឧបករណ៍អង្គួចក្នុងប្រទេសកម្ពុជា

https://jewsharpsociety.org/blog-list 01 / 2020

កម្មវិធីចំណេះដឹងអំពីសម្ភារៈដែលជិតបាត់បង់ នៃសារមន្ទីរនៃចក្រភពអង់គ្លេស បានគាំទ្រជាមូលនិធិដល់គម្រោងរយៈពេលមួយឆ្នាំ (ខែតុលា ឆ្នាំ ២០១៩ ដល់ ខែកញ្ញា ឆ្នាំ ២០២០) ដើម្បីថតនិងចងក្រងជាឯកសារ អំពី ឧបករណ៍ *«អង្គួច»* កម្ពុជា។ នេះគឺជាលើកទីមួយហើយ ដែលឧបករណ៍ *«អង្គួច»* កម្ពុជា ត្រូវបានថតនិងចងក្រងជាឯកសារឱ្យបានកាន់តែស៊ីជម្រៅ។

គម្រោងនេះ ត្រូវបានដឹកនាំដោយ ជាតិពិន្ទុតូរ្យតន្ត្រីវិទូ បណ្ឌិត ខាធជ្រីន ហ្វ្រាន (មកពីសាកលវិទ្យាល័យ ហ្វ្រីហ្វហ្វីធ ប្រទេសអូស្ត្រាលី) ជាមួយនឹងក្រុមការងារមកពី អង្គការសិល្បៈខ្មែរអមតៈ ពីរនាក់ទៀតគឺ លោក សុង សេង និង លោក ប៉ាទ្រីក ឃើសសាឡេ។



ក្រុមអ្នកស្រាវជ្រាវ (ពីឆ្វេងទៅស្ដាំ)៖ ថន ដីកា (អ្នកថតវីដេអូ), សាយ តុលា (ជំនួយការស្រាវជ្រាវ), បណ្ឌិត ខាធជ្រីន ហ្វ្រាន (អ្នកដឹកនាំគម្រោង), សុង សេង (ដៃគូសហការនៃគម្រោង), ប៉ាទ្រីក ឃើសសាឡេ (ដៃគូសហការនៃគម្រោង).
រូបថតដោយ៖ មិត្ត ណារុង. ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០២០

នៅប្រទេសកម្ពុជា *«អង្គួច»* ត្រូវបានគេរកឃើញនៅក្នុងបណ្តាខេត្តនានា ដោយវានៅជាមួយប្រជាជនខ្មែរ ដែលជាជនជាតិភាគច្រើន និងជាមួយប្រជាជនមួយចំនួននៃជនជាតិភាគតិច។ មុនសម័យខ្មែរក្រហម (១៩៧៥-១៩៧៩) ការផ្ទាត់និងចំណូលចិត្តឧបករណ៍អង្គួច មានប្រជាប្រិយភាពណាស់នៅតាមភូមិមួយចំនួន។ ប៉ុន្តែមកដល់ពេលនេះ ឧបករណ៍ និងការលេងផ្ទាត់ *«អង្គួច»* ស្ទើរតែបាត់បង់ទៅហើយ។

មុខងារនៃការលេងផ្ទាត់ឧបករណ៍អង្គួចរួមមាន៖ ផ្ទាត់ដើម្បីកំសាន្តសម្រាប់ប្រជាជននៅតាមទីជនបទ, ជាមធ្យោបាយមួយដែលប្រុសៗសម័យនោះប្រើសម្រាប់ទាក់ទង និងចែចង់ស្រីៗ, និងផ្ទាត់ដើម្បីធ្វើជាភ្លេងសម្រាប់ចម្រៀងព្រីន។ អ្នកធ្វើនិងអ្នកលេងអង្គួច ភាគច្រើនជាមនុស្សប្រុស បើទោះជាគ្មានការហាមឃាត់ណាមួយសម្រាប់មនុស្សស្រីក៏ដោយ។

នៅកម្ពុជា*«អង្គួច»* មានយ៉ាងហោចណាស់បីប្រភេទ៖អង្គួចឫស្សី,អង្គួចដែក និង អង្គួចខ្សែ។ នៅមិនទាន់ដឹងច្បាស់នៅឡើយទេ ថាតើនៅមានអ្នកចេះធ្វើឬលេងអង្គួចខ្សែ នៅក្នុងប្រទេសកម្ពុជាឬអត់នោះ។

ពេលខ្លះ យើងអាចឃើញអង្គួចឫស្សីមាននៅតាមភូមិមួយចំនួន ហើយអង្គួចឫស្សីនេះ ត្រូវបានគេធ្វើឡើងសម្រាប់លក់ទៅឱ្យភ្ញៀវទេសចរណ៍ធ្វើជាវត្ថុអនុស្សាវរីយ៍ទៀតផង។



អង្គួចដែលមិនទាន់ធ្វើរួចរបស់ លោក ជី មុនីវង់ កំពុងដាក់ហាលថ្ងៃឱ្យស្ងួត។
រូបថតដោយ៖ បណ្ឌិត ខាជគ្រើន ហ្រ្កាន. ថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០២០

សព្វថ្ងៃនេះ អង្គួចដែកស្ទើរតែបាត់បង់ទៅហើយ។



អង្គួចដែកដែលធ្វើដោយ លោកតា ប៊ិន សុង។
រូបភាពដោយ៖ បណ្ឌិត ខាជគ្រីន ហ្វ្រាន. ថ្ងៃទី ៦ ខែមករា ឆ្នាំ ២០២០

ក្រុមការងារបានចុះថតនិងធ្វើឯកសារអំពីអង្គួចនៅភូមិចំនួនពីរក្នុងខេត្តសៀមរាប ហើយក៏ជាភូមិដែលអ្នកធ្វើអង្គួចចំនួនបីនាក់កំពុងរស់នៅ។ នៅក្នុងភូមិស្រះស្រង់ខាងជើង មាន ព្រឹទ្ធាចារ្យ ក្រាក់ ជី អាយុ ៦៩ ឆ្នាំ និងកូនប្រុសពីរនាក់របស់គាត់ លោក ជី ចិន និង លោក ជី មុនីរង់ ជាអ្នកធ្វើអង្គួចឫស្សី។



ព្រឹទ្ធាចារ្យ ក្រាក់ ជី កំពុងធ្វើអង្គួចឫស្សី។
រូបភាពដោយ៖ បណ្ឌិត ខាធជ្រើន ហ្រ្កាន. ថ្ងៃទី ៥ ខែមករា ឆ្នាំ ២០២០

ព្រឹទ្ធាចារ្យ ក្រាក់ ជី ក៏ចេះផ្លាត់អង្គួចឫស្សីដែរ។



ព្រឹទ្ធាចារ្យ ក្រាក់ ជី កំពុងផ្លាត់អង្គួចឫស្សី។
វីដេអូដោយ៖ ថន ដីកា, ថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០២០

នៅភូមិព្រះគោថ្មី ឃុំស្វាយចេក លោកតា ប៊ិន សុង ក្នុងវ័យ ៧៨ ឆ្នាំ គឺជាអ្នកចេះធ្វើអង្កួចដែក ហើយប្រហែលជាមានតែគាត់ម្នាក់ទេដែលចេះនៅសម័យនេះ។ លោកតាមានមិត្តភក្តិតាំងពីកុមារភាពម្នាក់ឈ្មោះ លោកតា សុន សឿន ស្ថិតក្នុងវ័យ ៧៨ ឆ្នាំ ដូចគ្នា ហើយមានតែគាត់ម្នាក់ទេ ដែលក្រុមការងាររបស់យើងអាចបញ្ជាក់បានថា ជាអ្នកចេះផ្ទាត់ឧបករណ៍អង្កួច។



លោកតា សុន សឿន ផ្ទាត់អង្កួចដែក ជាមួយលោកតា ប៊ិន សុង ដែលត្រូវជាមិត្តតាំងពីកុមារភាព និងជាអ្នកធ្វើអង្កួចដែក។
រូបថតដោយ៖ ខាជគ្រីន ហ្វ្រាន, ថ្ងៃទី ១១ ខែមករា ឆ្នាំ ២០២០

លទ្ធផលសំខាន់នៃគម្រោងនេះ គឺជាវីដេអូឯកសារជាភាសាខ្មែររយៈពេល ២០ នាទី ជាមួយអក្សរអង់គ្លេសរត់ខាងក្រោម។ ក្រុមការងារក៏កំពុងតែបង្កើតឯកសារជាឌីជីថល ដែលក្នុងនោះមាន៖ រូបថត, ខ្សែអាត់សំឡេងនិងវីដេអូ ព្រមទាំងកូនសៀវភៅអំពីអង្កួច។ ឯកសារទាំងអស់នេះ នឹងផ្សព្វផ្សាយជាសាធារណៈនៅខែ តុលា ឆ្នាំ ២០២០ ។

ឯកសារទាំងអស់អំពីគម្រោង នឹងមានសម្រាប់សាធារណជនចូលទស្សនាដោយសេរីនៅ **បណ្ណសារដ្ឋាននៃសារមន្ទីរចក្រភពអង់គ្លេស**។ សម្រាប់អ្នកនៅកម្ពុជា អាចចូលទស្សនាវីដេអូឯកសារបាននៅ

**មជ្ឈមណ្ឌលបេតិកភណ្ឌ** ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណវត្តរាជបូណ៌ ក្រុងសៀមរាប និងនៅ **មជ្ឈមណ្ឌលសោតទស្សន៍បុប្ផាណា** ក្នុងទីក្រុងភ្នំពេញ។

អង្គការយូណេស្កូ ប្រចាំនៅកម្ពុជា បានចូលរួមបរិច្ចាគជាមូលនិធិ សម្រាប់ការចំណាយលើការរៀបចំកម្មវិធីផ្សព្វផ្សាយអំពីគម្រោង នៅឯមជ្ឈមណ្ឌលបេតិកភណ្ឌ ក្នុងក្រុងសៀមរាបនៅចុងឆ្នាំនេះ។ អ្នកធ្វើអង្គួច អ្នកផ្ទាត់អង្គួច ព្រមទាំងអ្នកភូមិរបស់ពួកគាត់មួយចំនួន នឹងត្រូវបានអញ្ជើញឱ្យមកចូលរួមក្នុងកម្មវិធីផ្សព្វផ្សាយនោះផងដែរ។ កម្មវិធីនេះ បើកទូលាយដល់សាធារណជនចូលរួមដោយសេរី !

**ទំនាក់ទំនង៖** ខាធឺរីន ហ្គ្រាន- catherine.grant@griffith.edu.au

EMKP
ENDANGERED MATERIAL
KNOWLEDGE PROGRAMME